# មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ បង្ហាញថា

# មគ្គុទ្ទេសក៍ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់មាតាបិតាក្នុងនាមជាដៃគូ ថ្នាក់ទី3

មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ ជឿទៅលើសំណុំមួយនៃជំនឿស្នូលអំពីគ្រួសារដែលយើងបម្រើជូនជារៀងរាល់ថ្ងៃ។

**ជំនឿគោល #1** មាតាបិតាទាំងអស់មានក្តីស្រមៃសម្រាប់កូនរបស់ខ្លួន និងចង់ឲ្យពួកគេល្អ

**ជំនឿគោល #2** ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់ចំពោះសមិទ្ធិផលនៃការសិក្សា

**ជំនឿគោល #3** មាតាបិតាទាំងអស់អាចគាំទ្រការសិក្សារបស់កូនរបស់ពួកគេបាន

**ជំនឿគោល #4** ការទទួលខុសត្រូវក្នុងការបង្កើតភាពជាដៃគូរវាងសាលា និងផ្ទះ ផ្អែកជាចំបងលើបុគ្គលិកសាលា ជាពិសេសថ្នាក់ដឹកនាំសាលា។

ពីព្រោះយើងប្រកាន់យកនូវជំនឿគោលលើការចូលរួមរបស់គ្រួសារ យើងបានបង្កើតសម្ភារ និងធនធានដើម្បីធានាថា គ្រួសារទាំងអស់យល់អំពី**ស្តង់ដារមុខវិជ្ជាស្នូល** និងអាចគាំទ្រការសិក្សានៅក្នុងផ្ទះ។ ធនធានទាំងនេះរួមមាន កញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ *(Common Core Backpack)* ដែលទាំងនោះគឺជាសកម្មភាពដែលមាតាបិតាអាចប្រើនៅផ្ទះ ដើម្បីពង្រឹងស្តង់ដារនៃមុខវិជ្ជាគោលទាំងនោះ។

| តើអ្វីគឺស្តង់ដារមុខវិជ្ជាស្នូល? | ហេតុអ្វីត្រូវការមុខវិជ្ជាស្នូល |
|---|---|
| កាលពីមុន រដ្ឋនិមួយៗមានកម្រិតស្តង់ដារអប់រំរបស់ខ្លួន។ ចំណុចនេះបានបង្កឲ្យមានការ ភាន់ច្រលំ និងក្តីបារម្ភណ៍អំពីថាតើសិស្សរបស់យើងត្រៀមខ្លួនសម្រាប់ចូល មហាវិទ្យាល័យ និងអាជីពការងារនៅក្នុងពេលបញ្ចប់ការសិក្សាពីវិទ្យាល័យ ឬអត់។ រដ្ឋកាលីហ្វ័រញ៉ាបានអនុម័តនូវស្តង់ដារមុខវិជ្ជាស្នូលនៅក្នុងឆ្នាំ 2010។<br><br>ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋ (CCSS) គឺជាការរំពឹងទុកនៃការសិក្សាមួយនៅក្នុងសិល្បៈ ភាសាអង់គ្លេស និងគណិតវិទ្យា ដែលបានបង្កើតឡើងដើម្បីត្រៀមសិស្សថ្នាក់ទី12 (K-12) ឲ្យចូលរៀនមហាវិទ្យាល័យ និងជោគជ័យអាជីពការងារ។ CCSS បង្ហាញឲ្យដឹងអំពីអ្វីដែល ត្រូវបានរំពឹងពីសិស្ស នៅតាមកម្រិតនិមួយៗដោយឲ្យសិស្ស មាតាបិតា គ្រូបង្រៀន និង អ្នកគ្រប់គ្រងសាលា ស្ថិតនៅក្នុងទីតាំងតែមួយដូចគ្នា ខណៈពេលកំពុងធ្វើការឆ្ពោះទៅរកគោលដៅរួមគ្នា។ | ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋគឺមានសារសំខាន់ពីព្រោះមុខវិជ្ជាទាំងនេះនឹង ជួយកុមារទាំងអស់ មិនថាពួកគេជានរណានោះទេ សុទ្ធតែរៀនជំនាញដូចគ្នាសម្រាប់ត្រៀមចូល មហាវិទ្យាល័យ និងអាជីពការងារ។ ពួកគេបង្កើតការរំពឹងទុច្បាស់លាស់មួយសម្រាប់ អ្វីដែលកូនរបស់អ្នកគួរដឹង និងអាចធ្វើ នៅក្នុងផ្នែកសំខាន់ផ្សេងៗ៖ អក្ខរកម្ម (**ការអាន សរសេរ និយាយ** និង**ស្តាប់**លើគ្រប់ផ្នែកនៃមុខវិជ្ជា) និង**គណិតវិទ្យា**។<br><br>ប្រសិនអ្នកដឹងការរំពឹងទុកទាំងនោះគឺជាអ្វី ក្រោយមកអ្នកអាចជួយកូនរបស់អ្នករៀបចំខ្លួន ពីព្រោះលោកអ្នកគឺជាគ្រូដំបូងរបស់កូនលោកអ្នក។<br><br>សិស្សរបស់យើងគឺជាអ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ អ្នកគ្រប់គ្រង និងអ្នករចនាប្លង់ នាពេលអនាគត។ ពួកគេគឺជាអ្នកដោះស្រាយបញ្ហា និងសហការ។ មុខវិជ្ជាស្នូលត្រៀម ធ្វើឲ្យពួកគេប្រកួតប្រជែងជាមួយ មិនមែនត្រឹមតែមិត្តភ័ក្រ្តជនជាតិ អាមេរិកកាំងនៅក្នុងរដ្ឋផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែជាមួយសិស្សដែលមកពីបណ្តាប្រទេសនានាលើពិភពលោក។ |

## តើគ្រួសារអាចគាំទ្រជោគជ័យរបស់សាលាដោយរបៀបណា?

ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់សម្រាប់ជោគជ័យនៃការសិក្សា។ និយាយយ៉ាងសាមញ្ញ សាលាមិនអាចអប់រំសិស្សតែម្នាក់ឯងបានទេ។ តើគ្រួសារអាចធ្វើជា
ដៃគូរជាមួយ សាលាបានដោយរបៀបណា?

1. ដឹងពីអ្វីដែលកូនរបស់អ្នកគួររៀននៅថ្នាក់ទី 3
2. សួរគ្រូថាតើកូនរបស់អ្នកមានទទួលជំនាញដែលបានបង្រៀនហើយឬនៅ

3. សួរថាតើលោកអ្នកអាចគាំទ្រការសិក្សានៅផ្ទះដោយរបៀបណា។ សួររកសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ *(Common Core Backpack)* ដែលគឺជាសកម្មភាព ដែលមាតាបិតាប្រើនៅផ្ទះជាមួយកូន ដើម្បីទទួលបានចំណេះដឹងពីស្តង់ដារមុខវិជ្ជាស្នូលទាំងនោះ។
4. អាន អាន អាន។ សូមឲ្យកូនរបស់លោកអ្នកអានជារៀងរាល់ថ្ងៃ និងសួរសំណួរទៅពួកគេ។ ក្រោយមកទៀត ឲ្យពួកគេទៅអានអត្ថបទដើម្បីឆ្លើយសំណួរ "តើអ្នកដឹងដោយរបៀបណា?
5. ត្រូវប្រាកដថា កូនរបស់លោកអ្នកគឺកំពុងអានសៀវភៅដែលមិនមែនជាប្រលោមលោកប្រឌិត ជាញឹកញាប់។

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់ទី 3

នេះគឺជាបំណិន **សិល្បៈភាសាអង់គ្លេស** សំខាន់មួយចំនួនដែលត្រូវយកមកបង្រៀននៅក្នុងថ្នាក់ទី3 ។ សម្រាប់តារាងស្តង់ដារមុខវិជ្ជាស្នូលរដ្ឋកាលីហ្វ័រញ៉ា សូមចូលទៅគេហទំព័រក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/).

មានសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល សម្រាប់ស្តង់ដារមុខវិជ្ជាស្នូលនិមួយដែលមានរៀបរាប់ក្នុងបញ្ជីខាងក្រោម:

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| RL.3.1 | សួរ និងឆ្លើយសំណួរដើម្បីបង្ហាញពីការយល់អត្ថបទមួយដោយផ្អែកទៅលើអត្ថបទជាក់ស្តែងដើម្បីជាមូលដ្ឋាននៃចម្លើយ។ | សួរ និងឆ្លើយសំណួរដើម្បីបង្ហាញថាពួកគេយល់ពីរឿងដែលកំពុងអាន។ |
| RL.3.2 | និទានរឿងឡើងវិញ រួមមានល្បើក រឿងព្រេង និងទេវកថាពីវប្បធម៌ចម្រុះ កំណត់ពីសារសំខាន់ៗ មេរៀន ឬតម្លៃអប់រំ និងពន្យល់ពីលក្ខណៈនៃការផ្ទេរព័ត៌មានតាមរយៈសេចក្តីលម្អិតសំខាន់ៗនៅក្នុងអត្ថបទ។ | និទានឡើងវិញនូវរឿងពីវប្បធម៌ចម្រុះ និងស្វែងរកមេរៀន ឬតម្លៃអប់រំនៃរឿង។ |
| RL.3.3 | ពណ៌នាអំពីតួអង្គនៅក្នុងរឿង (ឧ. បុគ្គលិកលក្ខណៈ: ការជម្រុញទឹកចិត្ត ឬអារម្មណ៍) និងពន្យល់ពីលក្ខណៈដែលសកម្មភាពរបស់ពួកគេចូលរួមចំណែកក្នុងលំដាប់លំដោយនៃព្រឹត្តិការណ៍។ | ពណ៌នាអំពីតួអង្គក្នុងរឿង និងពន្យល់ពីលក្ខណៈដែលសកម្មភាពរបស់ពួកគេមានឥទ្ធិពលនៅក្នុងរឿង។ |
| RL.3.6 | បង្ហាញពីភាពខុសគ្នាអំពីទស្សនៈរបស់អ្នកនិទាន ឬរបស់តួអង្គ។ | ប្រាប់ពីភាពខុសគ្នារវាងគំនិតរបស់ពួកគេ និងអ្នកនិពន្ធ ឬតួអង្គ។ |
| RI.3.3 | ពណ៌នាពីទំនាក់ទំនងរបស់សេរីនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ គំនិត ឬទស្សនៈបែបវិទ្យាសាស្ត្រ ឬជំហាននីតិវិធីបច្ចេកទេសនៅក្នុងអត្ថបទ ការប្រើប្រាស់ភាសាដែលមានទំនាក់ទំនងជាមួយនឹងពេលវេលា លំដាប់លំដោយ និងហេតុ/ផល។ | ពណ៌នាអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ គំនិតបែបវិទ្យាសាស្ត្រ ឬជំហាននៅក្នុងនីតិវិធីប្រើប្រាស់ពាក្យពេចន៍ដើម្បីបង្ហាញពីលំដាប់លំដោយ។ |
| RI.3.6 | បង្ហាញពីភាពខុសគ្នានៃទស្សនៈរបស់ពួកគេពីទស្សនៈរបស់អ្នកនិពន្ធ<br>អត្ថបទ។ | ប្រាប់ពីភាពខុសគ្នារវាងអ្វីដែលពួកគេគិត និងអ្វីដែលអ្នកនិពន្ធសរសេរ។ |
| RF.3.3 | ចេះ និងប្រើប្រាស់ពាក្យស័ព្ទតាមកម្រិតថ្នាក់ និងបំណិនវិភាគពាក្យនៅក្នុងការបកស្រាយពាក្យ។<br>a. កំណត់ និងដឹងពីអត្ថន័យនៃពាក្យបន្ថែមខាងដើម និងពាក្យបន្ថែមខាងចុងដែលគេនិយមប្រើជាទូទៅ។<br>b. បកស្រាយពាក្យដោយប្រើប្រាស់ពាក្យដែលគេនិយមបន្ថែមនៅខាងចុងរបស់ឡាទីន។<br>c. បកស្រាយពាក្យដែលមានច្រើនព្យាង្គ។<br>d. អានពាក្យដែលមានការប្រកបខុសពីប្រក្រតីដែលសាកសមនឹងកម្រិតថ្នាក់។ | អានពាក្យក្នុងថ្នាក់ទីបីដែលមិនមានការប្រកបតាមប្រក្រតី។ |
| RF.3.4 | អានបានយ៉ាងត្រឹមត្រូវ និងស្ទាត់ជំនាញគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការយល់ដឹង។<br>a. អានអត្ថបទតាមកម្រិតថ្នាក់ដោយមានគោលបំណង និងការយល់ដឹង។<br>b. អានពាក្យរាយ និងពាក្យកាព្យតាមលំដាប់ថ្នាក់ដោយ | អានបានយ៉ាងស្ទាត់ជំនាញ និងត្រឹមត្រូវដោយមានការបញ្ជាក់។ |

| | | |
|---|---|---|
| | ផ្ទាល់មាត់ មានអត្រាត្រឹមត្រូវ និងសំនួនវោហារស័ព្ទ អំពីអំណានបន្តបន្ទាប់គ្នា។<br>c. ប្រើបរិបទដើម្បីបញ្ជាក់អះអាង ឬស្វ័យកែតម្រូវការស្គាល់<br>ការយល់ និងការអានពាក្យណាមួយឡើងវិញតាមការចាំបាច់ | |

*ស្តង់ដារដែលមានភាពងាយស្រួលសម្រាប់មាតាបិតា ដែលដកស្រង់ពីលោក Jill និង Cathey Henry។ "I Can Standards." www.thecurricculumcorner.com. ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2012*

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់ទី 3

ទាំងនេះគឺជាបំណិន **<u>គណិតវិទ្យា</u>** សំខាន់ៗដែលកំពុងត្រូវបានបង្រៀននៅថ្នាក់ទី 3 ។ សម្រាប់បញ្ជីទាំងស្រុងស្តីពីស្តង់ដារមុខវិជ្ជាស្នូលរួមរបស់រដ្ឋកាលីហ្វ័រញ៉ា សូមមើល  វិបសាយរបស់ក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/)។

មានសកម្មភាពកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលសម្រាប់ស្តង់ដារមុខវិជ្ជាស្នូលរួមនីមួយៗ ដូចមានវាយឈ្មោះនៅខាងក្រោម។

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| 3.OA.1 | បកស្រាយផលគុណនៃចំនួនគត់ ឧ. បកស្រាយ 5 x 7 ដែលជាចំនួនសរុបនៃវត្ថុ 5 ក្រុម ដែលក្នុងមួយក្រុមៗមាន វត្ថុចំនួន 7។ ឧទាហរណ៍ ពណ៌នាបរិបទមួយដែលចំនួនសរុបនៃវត្ថុអាចបញ្ជាក់បានតាមរយៈ 5 x 7 ។ | យល់ពីវិធីគុណដោយគិតអំពីក្រុមនៃវត្ថុ។ |
| 3.OA.2 | បកស្រាយពីផលចែកជាចំនួនគត់ នៃចំនួនគត់ ឧ. បកស្រាយចំនួន 56 ÷ 8 ដែលជាចំនួននៃវត្ថុក្នុងចំណែកនីមួយៗ នៅពេលដែលវត្ថុចំនួន 56 ត្រូវបានបែកចែកជា 8 ចំណែកស្មើៗគ្នា ឬដែលជាចំនួននៃចំណែកនៅពេលវត្ថុ ទាំង 56 ត្រូវបានបែងចែកជា 8 ក្រុម ដែលមានចំណែកស្មើៗគ្នា។ ឧទាហរណ៍ ពណ៌នាពីបរិបទមួយដែលចំនួននៃចំណែក ឬចំនួននៃក្រុមអាចបញ្ជាក់បានតាមរយៈ 56 ÷ 8។ | យល់ពីវិធីចែកដោយគិតអំពីរបៀបដែលក្រុមមួយអាចបែងចែកជាក្រុមតូចៗ។ |
| 3.OA.3 | ប្រើវិធីគុណ និងវិធីចែកក្នុងរង្វង់ 100 ដើម្បីដោះស្រាយចំណោទក្នុងស្ថានភាពដែលទាក់ទងនឹងក្រុម លំដាប់ជួរ និងបរិមាណរង្វាស់ស្មើៗគ្នា ឧ. ដោយប្រើគំនូរ និងសមីការជាមួយនឹងនិមិត្តសញ្ញាសម្រាប់ចំនួនអញ្ញាតដើម្បីតំណាងឲ្យចំណោទនោះ។ 1 | ប្រើប្រាស់ចំណេះដឹងរបស់ពួកគេអំពីវិធីគុណ និងវិធីចែកដើម្បីដោះស្រាយចំណោទជាពាក្យ។ |
| 3.OA.5 | ប្រើប្រាស់លក្ខណៈនៃប្រមាណវិធីជាយុទ្ធសាស្ត្រក្នុងការគុណ និងចែក។ 2 ឧទាហរណ៍៖ ប្រសិនបើគេដឹងថា 6 x 4 = 24 ហើយដឹងថា 4 x 6 = 24 (វិធីគុណមានលក្ខណៈត្រឡប់)។ 3 x 5 x 2 អាចទទួលបានដោយ យក 3 x 5 = 15 រួច 15 x 2 = 30 ឬដោយ យក 5 x 2 = 10 រួច 3 x 10 = 30 (វិធីគុណមានលក្ខណៈចំរាស់)។ គេអាចទទួលបាន 8 x 7 ពី 8 x (5+2) = (8 x 5) + (8 x 2) = 40 + 16 = 57 (លក្ខណៈបែងចែក)។ | ប្រើប្រាស់វិធីគុណមានលក្ខណៈត្រលប់។ (បើ 6 x 4 = 25 នោះ 4 x 6 = 24) |
| 3.OA.8 | ដោះស្រាយចំណោទជាពាក្យដែលមានពីរជំហាន ដោយប្រើប្រាស់ប្រមាណវិធីចំនួន បួន។ តាងចំណោទទាំងនោះដោយប្រើប្រាស់សមីការ និងអញ្ញាតជាអក្សរតំណាងឲ្យចំនួនដែលមិនស្គាល់។ វាយតម្លៃភាពសមហេតុផលនៃចម្លើយដោយប្រើប្រាស់ការគណនាក្នុងខួរក្បាល និងយុទ្ធសាស្ត្រប៉ាន់ស្មានរួមទាំងការបង្គត់ចំនួន។ 3 | ប្រើប្រាស់វិធីបូក វិធីដក វិធីគុណ និងវិធីចែកដើម្បីដោះស្រាយចំណោទ និងប្រើប្រាស់គណិតវិទ្យាក្នុងខួរក្បាលដើម្បីសម្រេចថាតើចម្លើយមានភាពសមហេតុផលដែរ ឬទេ |
| 3.NBT.1 | ប្រើប្រាស់ចំណេះដឹងពីតម្លៃខ្ទង់ដើម្បីបង្គត់ចំនួនគត់ទៅជាខ្ទង់ 10 ឬ ខ្ទង់ ១០០ ដែលនៅកៀកបំផុត។ | បង្គត់ចំនួនគត់ទៅជាខ្ទង់ 10 ឬ ខ្ទង់ 100 ដែលនៅកៀកបំផុត។ |
| 3.NBT.2 | មានភាពស្ទាត់ជំនាញក្នុងការបូក និងដកក្នុងរង្វង់ 100 ដោយប្រើប្រាស់យុទ្ធសាស្ត្រ និងក្បួនដោះស្រាយបញ្ហាដែលផ្អែកលើតម្លៃខ្ទង់ លក្ខណៈនៃប្រមាណវិធី និង/ឬទំនាក់ទំនងរវាងវិធីបូក និងវិធីដក។ | បូក និងដកចំនួនក្នុងរង្វង់ 1000។ |
| 3.NF.1 | យល់ពីប្រភាគ 1/b ថាជាបរិមាណដែលបង្កើតដោយ 1 ភាគ នៅពេលដែលចំនួនទាំងមូលត្រូវបានបែងចែកទៅឲ្យ b ស្មើៗគ្នា និងយល់ពីប្រភាគ a/b ថាជាបរិមាណដែលបង្កើតដោយភាគមួយនៃទំហំ | បង្ហាញ និងយល់ថាប្រភាគគឺជាចំណែកស្មើៗគ្នានៃចំនួនទាំងមូល។ |

| | | |
|---|---|---|
| | 1/b។ | |
| 3.MD.1 | ប្រាប់ និងសរសេរម៉ោង រហូតដល់នាទីដែលនៅកៀកបំផុត និងគិតចន្លោះម៉ោងជា នាទី។ ដោះស្រាយចំណោទជាពាក្យដែលទាក់ទងនឹងវិធីបូក និង វិធីដកចន្លោះម៉ោងគិតជានាទី ឧ. ដោយគូសតាងចំណោទនៅលើដ្យាក្រាម បន្ទាត់លេខមួយ។ | ប្រាប់ និងសរសេរម៉ោងរហូតដល់នាទីដែលនៅកៀកបំផុត។ |
| 3.MD.8 | ដោះស្រាយចំណោទក្នុងពិភពជាក់ស្តែង និងក្នុងគណិតវិទ្យាដែលពាក់ព័ន្ធនឹង បរិមាត្រនៃពហុកោណ រួមទាំងការរក បរិមាត្រ ជាមួយនឹងរង្វាស់ជ្រុងដែលគេប្រាប់ គណនារង្វាស់ជ្រុង និងគូសតាង ចតុកោណដែលមានបរិមាត្រដូចគ្នា និងក្រលាផ្ទៃខុសគ្នា ឬក្រលាផ្ទៃដូចគ្នា និងបរិមាត្រខុសគ្នា។ | ដោះស្រាយចំណោទក្នុងពិភពជាក់ស្តែង និងក្នុងគណិតវិទ្យាដោយប្រើប្រាស់ចំណេះដឹងអំពីបរិមាត្រនៃរាងផ្សេងៗ។ |

*ស្តង់ដារដែលមានភាពងាយស្រួលសម្រាប់មាតាបិតា ដែលដកស្រង់ពីលោក Jill និង Cathey Henry។ "I Can Standards." www.thecurricculumcorner.com. ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2012*